**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការខេត្តកំពង់ធំ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៤០៥ ចុះថ្ងៃទី ០៣
ខែ តុលា ឆ្នាំ ២០០១
សាលក្រមព្រហ្មទណ្ឌ
លេខ ៧៧ គ ចុះថ្ងៃទី ១២
ខែ កក្កដា ឆ្នាំ ២០០៤

*សាលក្រមនេះបានចូលស្ថាពរកាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០៤ រួចហើយ*
*ដោយគ្មានគូក្តីណាចូលមកប្តឹងតាមកំណត់ច្បាប់ ។*
*កំពង់ធំ, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥*
**ចៅក្រមជំនុំជំរះ**
[redacted]

**នាមនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តកំពង់ធំ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជំរះតុលាការខេត្តកំពង់ធំ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោកស្រី [redacted] អនុប្រធានតុលាការខេត្តកំពង់ធំ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្តកំពង់ធំ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីតុលាការខេត្តកំពង់ធំ

**ដើម្បីជំនុំជំរះ :**

-ឈ្មោះ **ច គឃ** ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ កើតនឹងរស់នៅសព្វថ្ងៃ ភូមិលាបទង ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ សាសនាព្រះពុទ្ធ របររកស៊ីធ្វើស្រែ ប្រពន្ធឈ្មោះ **ស ខ** មានកូន ០២នាក់ ឪពុកឈ្មោះ **ឆ គឈ** (រ) ម្តាយឈ្មោះ **ប ៩** (រ) ទោសពីមុនគ្មាន ។

-ឈ្មោះ **ច គ៩** ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ កើតនឹងរស់នៅសព្វថ្ងៃ ភូមិលាបទង ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ សាសនាព្រះពុទ្ធ មុខរបររកស៊ីធ្វើស្រែ ប្រពន្ធឈ្មោះ **ស ៨** មានកូន ០២នាក់ ឪពុកឈ្មោះ **ឆ គឈ** (រ) ម្តាយឈ្មោះ **ប ៩** (រ) ទោសពីមុនគ្មាន ។

-ឈ្មោះ **ឥ សឧ** ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ កើតនឹងរស់នៅសព្វថ្ងៃ ភូមិលាបទង ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ ប្រពន្ធឈ្មោះ **ច ឆអ** មានកូន ០២នាក់ ឪពុកឈ្មោះ **ឥ ត** (ស) ម្តាយឈ្មោះ **ហ អ** (រ) ។ សាសនាព្រះពុទ្ធ មុខរបរធ្វើស្រែ ទោសពីមុនគ្មាន ។

អ្នកទាំងបីខាងលើពីបទ បង្ករបួសស្នាមចេតនា ប្រព្រឹត្តនៅភូមិលាបទង ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ កាលពីថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០១ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **យ សទរ** ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិក្តី ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ ។



Scanned with CamScanner

ប្តឹងថា កាលពីថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០១ វេលាម៉ោង ៨:០០យប់ ខ្ញុំខឹងនឹងឪពុកម្តាយ ចាំទៅលេង កំពង់ធំដោយមានលុយកាក់ ២០ម៉ឺនរៀល និង៣០០ដុល្លា ខ្ញុំឈរចាំឡាននៅមុខផ្ទះឈ្មោះ **ស សម** ដោយឈរនៅ ចិញ្ចើមថ្នល់ ស្រាប់តែមានម៉ូតូអឹមដេមួយគ្រឿងជិះគ្នា ០៣នាក់ បានមកឈប់ម៉ូតូព្រួតគ្នាទាំងបីនាក់ មកវ៉ៃខ្ញុំម្តង តែម្តង បណ្តាលឱ្យដួលសន្លប់បាត់ស្មារតី ពេលដឹងខ្លួននៅមន្ទីរពេទ្យ មានរបួសស្នាមជាទម្ងន់ បាត់ប្រាក់ ២០ម៉ឺន រៀល ប្រាក់ ៣០០ដុល្លា នាឡិកាដៃម៉ាករ៉ាដូមួយគ្រឿងតម្លៃ ៩០ដុល្លា ។

-ដីកាសន្និដ្ឋានស្ថាពរលេខ ៣០៩ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៣ របស់ព្រះរាជអាជ្ញាអមតុលាការ ខេត្តកំពង់ធំ ។

-ដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ៦០៤ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៣ របស់ចៅក្រមស៊ើបសួរ ។

-ដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ៦០៥ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៣ របស់ប្រធានតុលាការ ខេត្តកំពង់ធំ ។

## ងរឿងហេតុមានដូចតទៅ :

វេលាយប់ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០១ ឈ្មោះ **យ សទរ** ខឹងម្តាយស្តីបន្ទោស ក៏លួចយកប្រាក់ ២០ម៉ឺនរៀល និង៣០០ដុល្លា រួចទៅឈរចាំរថយន្តជិះមកកំពង់ធំ នៅភូមិលាបទង ឃុំកំពង់ចិនត្បូង ឈរនៅ ក្រោមដើមខ្នុរមុខផ្ទះឈ្មោះ **ស សមល** ហើយខ្លាចគេស្គាល់យកអាវគ្របមុខ ចំពេលនោះឈ្មោះ **ច គហ**, **ច គទ** និងឈ្មោះ **គ សឧ** ជិះម៉ូតូមកពីផ្ទះក្រពើបានឃើញឈប់ម៉ូតូចូលទៅសួរ ។ ឈ្មោះ **ច គហ** ដាល់ឈ្មោះ **ស ទរ** តែម្តងបណ្តាលឱ្យដួលអុកតួច ឯឈ្មោះ **ច គថ** និងឈ្មោះ **ថ សឧ** នាំគ្នាព្រួតវាយបន្ថែម បណ្តាលឱ្យឈ្មោះ **យ សទរ** សន្លប់ ។

## នារពលសទនាការ

-ជនជាប់ចោទឈ្មោះ **ច គថ** បានឆ្លើយបញ្ជាក់ថា : កាលពីថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០១ ខ្ញុំនាំបងប្អូន បីនាក់ទៅផ្ទះក្រពើនៅវត្តព្រះរាង ដោយក្រពើគេរួច ម៉ោង៨:៣០នាទី នាំគ្នាត្រឡប់មកវិញ ជិះម៉ូតូមកជិតមុខផ្ទះ ឃើញមនុស្សរត់ចេញពីក្រោមផ្ទះ ឆ្លងថ្នល់មកជ្រកដើមខ្នុរ ខ្ញុំចុះពីលើម៉ូតូឈ្ងូលកែវតាមសួរ ។ ខ្ញុំសួរអ្នកណា។ ៤-៥ម៉ាត់ វាឥតឆ្លើយទេ ខ្ញុំថាអានេះបែបនេះមនុស្សឆ្កួតហើយ ក៏យកម៉ូតូទៅទុក ខ្ញុំសួរម្តងទៀតវាបើកមុខ ក៏ឆ្លើយថាអញចង់យ៉ាងម៉េច ខ្ញុំថាអា **រ** គ្នាទេ វារុញដើមទ្រូងខ្ញុំ ខ្ញុំថយរហូតជណ្តើរផ្ទះ ឈ្មោះ **ឋា** ជាប្អូនខ្ញុំសួរថា ហ្អែងចង់យ៉ាងម៉េច ឈ្មោះ **រ** ងាកទៅក្រោយជាមួយឈ្មោះ **ឋា** នាំដាល់ត្រូវមុខមួយដៃដួល វាក្រោកឡើងប្រុងស្ទុះ មកវ៉ៃទៀត ឪពុកម្តាយខ្ញុំគាត់ឮ គាត់ចុះមកសួរ ថាវាខឹងនឹងម្តាយ គាត់ចាប់ដៃវាឃើញឈាមហូរវាថាអារដៃខ្លួនរ គាត់យកប្រេងកូឡាមកឃាត់ឈាមនឹងលាបមុខវា ។ បានមួយសន្ទុះបងប្អូនវាមកដល់គុកកាក់ ពួកខ្ញុំឡើងលើផ្ទះ បិទទ្វារ ព្រោះឃើញឈ្មោះ **ម៉ាម់** មានកាំភ្លើងខ្លីមួយដើម ។ ពួកវាវ៉ៃពាង ចោលដំបូលផ្ទះ ចោលផ្ទាំគគណបក បែកដំបូលផ្ទះច្រើនកន្លែង ប្រមាថហៅឪពុកម្តាយខ្ញុំចុះមកសម្លាប់ចោលថែមទៀត ខ្ញុំលបមើលឃើញបក្សពួក ច្រើនណាស់ ប្រហែលជា ១០នាក់ ខ្ញុំស្គាល់ ០៤នាក់ អា **រ** ឈ្មោះ ម៉ាប់ ឈ្មោះ **ម** ឈ្មោះ **ឈា** ។ ខ្ញុំមិនដឹងនណាជេរ គប់ដំបូលផ្ទះ និងវ៉ៃពាងទេ ។ សូមតុលាការជួយរកយុត្តិធម៌ផង ។

-ជនជាប់ចោទឈ្មោះ **ច គហ** បានឆ្លើយថា : កាលពីយប់ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០១ ខ្ញុំបបួល បីនាក់ជាបងប្អូនខ្ញុំឈ្មោះ **ច គថ** ឈ្មោះ **ឥ សឧ** ហៅ **យ** និងរូបខ្ញុំ បាននាំគ្នាទៅផ្ទះក្រពើដែលរួចនៅវត្តព្រះរាង



Scanned with CamScanner

ដល់ម៉ោង ៨:៣០នាទីយប់ ខ្ញុំត្រលប់មកពីផ្ទះវិញ ជិះម៉ូតូឌុបគ្នាបីនាក់ មកដល់មុខផ្ទះឃើញពន្លឺភ្លើងម៉ូតូមានមនុស្សម្នាក់រត់ចេញពីក្រោមផ្ទះខ្ញុំឆ្លងថ្នល់មកក្រោមដើមខ្នុរ ដោយយកអាវយឺតដៃវែងគ្រប់មុខអង្គុយនឹងដី ។ បាននាំគ្នាឈប់ម៉ូតូច្របាច់ភ្លើងកែវតាមសួរវា បង **ច គ៩** សួរអាណា វាឆ្លើយថាអញ ហ្អែងចង់យ៉ាងម៉េច វាងើបឈរដេញវាយបងខ្ញុំតែម្តង បងខ្ញុំគេចថយរហូតកាំជណ្តើរផ្ទះនឹងឡើងបានបីកាំ ខ្ញុំសួរវាយ៉ាងម៉េច វាបកមកវាយខ្ញុំតែខុស ខ្ញុំវាយវាមួយដៃវិញត្រូវចំមុខវាខាងឆ្វេង វាអុកក្តិតមុខផ្ទះ វាក្រោកប្រុងតខ្ញុំ បានអ្នកជិតខាងឈ្មោះ **ឆា** ជាងម៉ូតូចាប់ដៃវាជាប់ ។ ដៃមានឈាមវាខឹងម្តាយវាអារដៃខ្លួនឯង ប៉ាខ្ញុំយកប្រេងកូឡាលាបដៃឱ្យវា ។ ពេលនោះអ្នកជិះម៉ូតូមកដល់រករឿងពួកខ្ញុំ ក៏នាំគ្នាគេចចូលផ្ទះបិទទ្វារ ។ វាស្រែកសំលាប់ចោល ចោលបែកពាង ។ សូមតុលាការជួយរកយុត្តិធមិឱ្យផង ។

-ជនជាប់ចោទឈ្មោះ **ឆ សឧ** បានឆ្លើយបញ្ជាក់ថា : នៅយប់ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០១ ខ្ញុំចាំបងប្អូនបីនាក់ទៅឆ្ពះរកក្រពើដែលរួចនៅសាលាវត្តព្រះរាង ប្រហែលម៉ោង៨:៣០នាទីយប់ នាំគ្នាត្រឡប់មកវិញជិះម៉ូតូបីនាក់ មកដល់ជិតផ្ទះឃើញមនុស្សបិទមុខរត់ចេញពីក្រោមផ្ទះ ឆ្លងថ្នល់ទៅច្រកក្រោមដើមខ្នុរមុខផ្ទះបង **៩** ច្របាច់ភ្លើងកែវតាមសួរពីរបីម៉ាត់ តែឥតឆ្លើយ គាត់ថាប្រហែលមនុស្សឆ្កួត ក្រោយមកវាឆ្លើយថាអញ ក៏វាដេញវៃមកបង **៩** តែម្តង វាបើកមុខបង **៩** ក៏រត់មកនៅនឹងជណ្តើរផ្ទះ វាក៏បកមករកវៃអា **ម** អា **ម** ដាល់ត្រូវមុខមួយដៃ ថាម៉េចវៃអញ អា **ម** ឆ្លើយថា អញវាយការពារខ្លួន បើហ្អែងមានកាំបិតចាក់អញងាប់ ឮសំលេងឪពុកម្តាយក្មេកខ្ញុំចុះមកឃើញដៃវាឈាម គាត់សួរ វាថាខឹងម្តាយវាអារដៃខ្លួនឯង ។ ប៉ាខ្ញុំជួយឃាត់ឈាមវា លាបប្រេងកូឡា អា **យ** ដាល់មួយដៃ ។ ប្រហែល ១០នាទី គ្នាវាពីរនាក់ជិះម៉ូតូមកដល់ ចោទពួកខ្ញុំវាយប្អូនវា វាថាអាណាខ្លាំងចេញមក វាហៅគ្នាវាមកទៀតមានជាច្រើន ខ្ញុំស្គាល់ប្អូននាក់ ឈ្មោះ **ម** ឈ្មោះ ម៉ាប់ ឈ្មោះ **ណា** និងឈ្មោះ **រ** ។ ពេលនោះពួកខ្ញុំឡើងលើផ្ទះបិទទ្វារ ពួកវាហៅប៉ាក្មេកឱ្យចុះមក វាប្រមាថកាប់ចោល រួចវាយពាង ចោលដំបូលផ្ទះ គប់ផ្ទាំងគណបក្ស ចោលគោយន្តក្រោមផ្ទះ ប្រមាថដុតផ្ទះ គ្នាវាមានពី ០៩នាក់ ទៅ ១០នាក់ ប្រហែលម៉ោងមួយយប់បានវាត្រឡប់ទៅវិញ ។ ខ្ញុំមិនបានវាយទៅឈ្មោះ **រ** ទេ អ្នកវាយឈ្មោះ **ម** ខ្ញុំមិនដឹងនរណាមួយគប់ផ្ទះទេ ។ សូមតុលាការជួយរកយុត្តិធមិផង ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **យ សខរ** បានឆ្លើយបញ្ជាក់ថា : កាលពីថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០១ វេលាម៉ោង ០៧ជាង ខ្ញុំសុំម៉ូតូម្តាយជិះដើរលេង គាត់ហាមខ្ញុំមិនឱ្យដើរលេងទេ ខ្ញុំខឹងចូលយកលុយក្នុងកាបូបគាត់ប្រាក់ ២០ម៉ឺនរៀល និង៣០០ដុល្លាអាមេរិច ខ្ញុំពាក់នាឡិកាមួយ ខ្ញុំដើរចេញពីផ្ទះឱ្យបងជីដូនមួយឌុបម៉ូតូមកផ្ទះយាយនៅភូមិលាបទង បងឈ្មោះ **ម ឆរ** ហៅ **ស** ។ ខ្ញុំចង់ដេកផ្ទះយាយ **ភ ខឡ** តែម្តាយជិះម៉ូតូតាមរកខ្ញុំបានឃើញខ្ញុំនៅផ្ទះយាយ គាត់ជិះម៉ូតូបកទៅវិញ ខ្ញុំខ្លាចម៉ែមកយកលុយ បានចេញពីផ្ទះយាយបំរុងរកឡានជិះមកកំពង់ធំដេកផ្ទះអ៊ុំ **ភ ចណ** បានដើរមកឈប់មុខផ្ទះអ៊ុំ **ស សមល** អង្គុយលើគ្រែក្រោមដើមខ្នុរចាំឡាន មានភ្លើងបំភ្លឺផ្លូវប្រវែង ០៦តឹក ពេលនោះម៉ោង ០៨ជាង ខ្ញុំអង្គុយមួយសន្ទុះឃើញភ្លើងម៉ូតូជិះមក ខ្ញុំខ្លាចបងប្អូនគេមកតាមហៅខ្ញុំ ខ្ញុំយកអាវគ្របមុខកុំឱ្យស្គាល់ គេជិះមកដល់ខ្ញុំស្គាល់ជាគូ **ធី ខត្ថារៈ** ហៅ តៃ គាត់មើលមកខ្ញុំមិនស្គាល់គាត់ជិះហួសទៅ មានឡានទីសាន់មកដល់ខ្ញុំហៅឡានជិះ តែគេមិនដាក់ឱ្យមានឥវ៉ាន់ពេញឡាន ខ្ញុំមកអង្គុយបានឃើញម៉ូតូមួយទៀត ខ្ញុំយកអាវទទូលក្បាល មានម៉ូតូនោះមកដល់បានហៅខ្ញុំ វាឈប់ម្ខាងថ្នល់រួចដាក់ចន្ទុលម៉ូតូមានគ្នា ០៣នាក់ វាស្រែកសួរខ្ញុំអាណាអង្គុយ ខ្ញុំស្គាល់ឈ្មោះ **ច គម** ខ្ញុំទំលាក់អាវពីលើក្បាលងើបឈរដើរទៅបំរុងប្រាប់វាថាចាំឡានទេ ។ វាទាំង ០៣នាក់ដើរមកឈរកណ្តាលថ្នល់ ខ្ញុំដើរចូលទៅថាអញ ខ្ញុំដើរជិតដល់វា វាថាអា **រ**

កូនប៉ិះចាន់ទេ វាដាល់ខ្ញុំមួយដៃចំសៀតថ្គាខាងឆ្វេងយ៉ាងខ្លាំង ខ្ញុំវិលដួលព្រុះតែម្តង រកនិយាយស្តីមិនកើតភាំងស្មារតីមួយសន្ទុះខ្ញុំបានសួរថា ខ្ញុំធ្វើអីបងឯងបានជាវ៉ៃខ្ញុំ ខ្ញុំប្រឹងងើបស្រាប់តែអាពីរនាក់គ្នាវាមកវាយខ្ញុំថែមទៀត ទាត់ផង ធាក់ផង ដាល់ផង ខ្ញុំភាំងស្មារតី ឃើញភ្លើងមកដល់វាឈប់វាយ ឮមាត់គេសួរថាអាណាកើតអី ខ្ញុំស្រែកឱ្យគេជួយផងគេវាយខ្ញុំ គេឈប់ម៉ូតូអ្នកវាយថយក្រោយ ពួនោះមកចាប់លើកខ្ញុំដែលដួលដេកលើដី បងជីដូនមួយបានទៅហៅឪពុកម្តាយខ្ញុំ ខ្ញុំសន្លប់លែងដឹងខ្លួន ។ ខ្ញុំបាត់លុយ ២០ម៉ឺនរៀល និងប្រាក់ដុល្លា ៣០០ដុល្លា។ សុំឱ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ មិនទាមទារសំណង និងជម្ងឺចិត្តអ្វីទេ សុំឱ្យបញ្ចប់រឿង ។

-បានអានចម្លើយសាក្សីដាក់បន្ទុកឈ្មោះ **ស សមល** បានឆ្លើយបញ្ជាក់ថា : កាលពីយប់ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០១ ខ្ញុំនៅផ្ទះវេលាម៉ោង ៨:៤០នាទី ខ្ញុំចុះពីលើផ្ទះឃើញមនុស្សម្នាក់ពាក់អាវដូចទទូលក្បាលអង្គុយនឹងដី ក្បែរបង្គោលរបងព្រំដីក្រោមដើមខ្នុរ មិនមាននណោរអង្គុយទេ មុខផ្ទះខ្ញុំមានដាក់អំពូលភ្លើងនៅជាប់ដើមម្សៀន ។ ស្រាប់តែម៉ុកូនចៅអ្នក **ល** មកអូសដៃវាយកទៅ ក៏ប្រទូសសារាយគ្នានឹងថ្នល់មុខផ្ទះឈ្មោះ **ឈ អ** ខ្ញុំស្មានតែបងប្អូនវាឈ្លោះគ្នា ព្រោះកន្លងមកធ្លាប់ឈ្លោះគ្នាពីរដងរួចមកហើយ ខ្ញុំមិនហ៊ានចេញទៅជួយទេ មកឈរបាំងតូប មើលបានឮសូរសំលេងអា **រ** ថាម៉េចក៏វ៉ៃខ្ញុំ ខ្ញុំឃើញអា **រ** ដួលមិនងើបរួចទេ បានឃើញអ្នក **ល** និងប្រពន្ធចុះពីលើផ្ទះមកមើល អា **រ** ថា យកប្រេងកូឡាមកលាប អា **រ** គ្នាវាមកវាយ ០៣នាក់ដែលគ្មានអ្វីតជាមួយគេទេ ។ បានប្អូនអា **រ** មកដល់ម្ខាងទៀតឡើងលើផ្ទះបិទទ្វារ ក្រោយមកមានមនុស្សមកជាច្រើនឮព្រៃព្រួមិនដឹងគេធ្វើអីទេ ។ ឯអ្នករបួសគេដឹកទៅមន្ទីរពេទ្យ ។ ឪពុកអា **រ** បានហៅអ្នក **ល** ចុះមកសម្រួលគេមិនចុះមិនមានឆ្លើយ ។ ឈ្មោះអ្នក **ល** មិនត្រូវខឹងគេឯងទាំងឪពុកកូនមានភាពច្រងេងច្រង៉ាងមិនមានអ្នករ៉ាប់រកទេ ។

-បានអានចម្លើយសាក្សីដាក់បន្ទុក **ភ រ** បានឆ្លើយបញ្ជាក់ថា : កាលពីថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៥ វេលាម៉ោង ៨:២០នាទីយប់ ខ្ញុំកាន់ខ្សែដើរចេញពីក្រោមផ្ទះមកខាងមុខ ឃើញមនុស្សម្នាក់ដើរពីត្បូងមកជើងតាមថ្នល់អែបមុខផ្ទះ ខ្ញុំទៅដល់បង្គោលផ្លាកគណបក្សហ្វុនស៊ីប៉ិច ឃើញឡានមកពីជើងវាហៅឡានឱ្យឈប់ថាទៅកំពង់ធំឡានចង្អៀតមិនបានជិះទៅទេ ម្នាក់នេះដើរទៅជើងទៀត ទៅឈប់ក្រោមដើមខ្នុរមុខផ្ទះ **ស មល** ហើយយកអាវទទូលក្បាល ។ ប្រហែល ១០នាទីឃើញម៉ូតូមួយជិះគ្នា ០៣នាក់មកពីជើងវាឃើញមនុស្សអង្គុយឆ្វៃលម៉ូតូបញ្ចាំងភ្លើងដាក់ ក៏ឈ្មោះ **គ ៩** ចុះពីលើម៉ូតូទៅឈរពាក់កណ្តាលថ្នល់ សួរថាអ្នកណាអង្គុយ មនុស្សឆ្លើយថា ខ្ញុំអង្គុយពួនម៉ែខ្ញុំទេ កុំឱ្យគេរកឃើញ ។ អ្នកទាំងបីដើរទៅ អាអង្គុយក្រោកដើរទៅជួបគ្នានៅកណ្តាលថ្នល់ អាបីនាក់ថាគ្នាឯងទេតើ ឈ្មោះ **គ ៩** ចេះតែសួរថា ឯងទទូលអាវនេះប្រុងធ្វើអ្វី សួរបណ្តើរកៀងបណ្តើរទៅដល់មុខផ្ទះឈ្មោះ **ឈ អ** ។ មនុស្សនោះថាវាទទូលអាវពួនម៉ែប្រុងទៅកំពង់ធំ ចេះតែសួរៗ ស្រាប់តែឈ្មោះ **ល ឃ** ដាល់មួយដៃអុកតូចតែម្តង អា **រ** ងើបឡើងថាម៉េចបានជាដាល់ខ្ញុំ បាននិយាយតទៅតមក អ្នក **ល** និងប្រពន្ធចុះមកជួយលាបប្រេងកូឡាអោយ ឈ្មោះ **រ** ហើយដេញឱ្យ **រ** ឆាប់ទៅផ្ទះ ។ ក្រោយមកមានបងប្អូនអ្នករងគ្រោះមកដល់ ឈ្មោះអ្នក **ល** ហៅកូនឡើងលើផ្ទះ ហើយពួកនេះហៅអ្នក **ល** ចុះមកដីដើម្បីនិយាយគ្នា តែពួកនេះមិនចុះមកទេ អ្នកនៅដីរើសដុំថ្មចោលពាងទឹកបែក តែមិនដឹងអ្នកណាមួយទេ ។ អ្នក **ល** មានភាពច្រងើងច្រង៉ាងណាស់ ។

-វិញ្ញាបនប័ត្ររបស់ការិយាល័យសុខាភិបាលប្រតិបត្តិស្រុកស្ទោងថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០១ បានបញ្ជាក់ថា : បានពិនិត្យឈ្មោះ **យ សរ** ភេទប្រុស អាយុ ២០ឆ្នាំ សភាពអ្នកជម្ងឺពេលចូលពេទ្យមានស្មារតីធម្មតាឈឺក្បាលវិលមុខចង់ក្អួត ។



Scanned with CamScanner

-ហើយនៅកដៃខាងឆ្វេងព្រមទាំងមានស្លាកស្នាមរបួសប្រវែងប្រហែល ០៣សង់ទីម៉ែត្រ ជម្រៅ ១០សង់ទីម៉ែត ។

ការសន្និដ្ឋានអ្នករងគ្រោះពិតជាទទួលការប៉ះទង្គិចក្បាលក្នុងកំរិតរញ្ជួយមធ្យម និង ជាសះស្បើយក្នុងរយៈ ០៧ថ្ងៃក្រោយការព្យាបាល ។

-កំណត់ហេតុទទួលវត្ថុតាងអយ្យការថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០២ មានស្បែកជើងពណ៌ខ្មៅម៉ាក់គីតូចំនួន ០១គូ (ចាស់) ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា : អយ្យការរក្សាបទចោទប្រកាន់ដដែល សូមតុលាការសម្រេចសេចក្តីទៅតាមច្បាប់ ។

-បានស្តាប់ចម្លើយជនជាប់ចោទ

-បានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-បានស្តាប់ចម្លើយសាក្សី

-បានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

**<u>តុលាការខេត្តកំពង់ធំ</u>**

បានពិនិត្យសំណុំរឿងចប់សព្វគ្រប់

**<u>យល់ឃើញថា</u>**

-យល់ឃើញថា : យប់ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០១ ឈ្មោះ ច គឃ. ច គថ និងឈ្មោះ ឆ សន រួមគ្នាបង្ករបួសស្នាមលើឈ្មោះ យ សរ ។

-យល់ឃើញថា : ឈ្មោះ ច គឃ ចូលទៅដល់អ្នករងគ្រោះ រួចឈ្មោះ ច គថ និងឈ្មោះ ឆ សន ចូលទៅជួយវាយដែរ ធ្វើឱ្យអ្នករងគ្រោះមានរបួសស្លាកស្នាម ។

-យល់ឃើញថា : ជនល្មើសទាំង ០៣នាក់ វាយជនរងគ្រោះ រួចរត់ឡើងលើផ្ទះបិទទ្វារ ។

-យល់ឃើញថា : តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា រក្សាបទចោទដដែល សូមតុលាការសម្រេចក្តីទៅតាមច្បាប់ ។

-យល់ឃើញថា : ដើមបណ្តឹងរដ្ឋប្បវេណីនិងជាជនរងគ្រោះ សុំឱ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ មិនទាមទារសំណងអ្វីទៀតទេ សុំឱ្យបញ្ចប់រឿង ។

-យល់ឃើញថា : ឈ្មោះ ច គឃ. ឈ្មោះ គ ថ និងឈ្មោះ ឆ សន ល្មើសនឹងមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**<u>ហេតុដូច្នេះតុលាការខេត្តកំពង់ធំ</u>**

**<u>វិនិច្ឆ័យសេចក្តី</u>**

(ឆ្ន៧

១-ផ្តន្ទាទោសឈ្មោះ ច គឃ ភេទប្រុស អាយុ ២៤ឆ្នាំ ឈ្មោះ ច គថ ភេទប្រុស អាយុ ៣០ឆ្នាំ ឈ្មោះ ឆ សគ ភេទប្រុស អាយុ ២៥ឆ្នាំ ម្នាក់ៗដាក់ពន្ធនាគារ ០៦ខែ តែទោសនេះត្រូវព្យួររយៈពេលសាកល្បង ០៥ឆ្នាំ ។ ពីបទ បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិលាបទង ឃុំកំពង់ចិនត្បូង



Scanned with CamScanner

ស្រុកស្ទោងខេត្តកំពង់ធំកាលពីថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០១ ។ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤១-៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ទោសខាងលើនេះគិតតាំងពីសាលក្រមអនុវត្តស្ថាពរតទៅ ។

២-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ចៅក្រមជំនុំជំរះ

ហត្ថលេខា និងត្រា [redacted]

បានឃើញ

ចៅក្រមជំនុំជំរះតុលាការខេត្តកំពង់ធំ

[redacted]

Scanned with CamScanner